I - ទីស្តីការគណៈរដ្ឋមន្ត្រី

អនុក្រឹត្យ

រាជធានីភ្នំពេញ,ថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ១៩៩៤

អនុក្រឹត្យលេខ ២៤ អនក្រ.ពហ

ស្តីពីការផ្ទេរសាលាមធ្យមសិក្សាឯកទេសពាណិជ្ជកម្ម

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុវរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

សំរេច

មាត្រា ១ : ផ្ទេរសាលាមធ្យមសិក្សាឯកទេសពាណិជ្ជកម្ម របស់ក្រសួងពាណិជ្ជកម្ម ព្រមទាំងចលនវត្ថុ និង អចលនវត្ថុទាំងអស់ អោយស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងអប់រំ យុវជន និង កីឡា ។

មាត្រា ២ : ចំពោះការផ្ទេរក្របខ័ណ្ឌមន្ត្រី រាជការរបស់សាលានេះ ក្រសួងពាណិជ្ជកម្ម និង ក្រសួងអប់រំយុវជន និង កីឡា ត្រូវពិភាក្សាគ្នាតាមសភាពជាក់ស្តែង ។

មាត្រា ៣ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា និង ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀង ៗ ខ្លួន ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី១	នាយករដ្ឋមន្ត្រីទី២
ព្រះហស្តលេខានិងត្រា	ហត្ថលេខា និងត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

រាជធានីភ្នំពេញ,ថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ១៩៩៤

អនុក្រឹត្យលេខ ២៥ អនក្រ
ស្តីពីការរៀបចំនិងរចនាសម្ព័ន្ធដឹកនាំនៃកងរាជអាវុធហត្ថ

* * *

រាជរដ្ឋាភិបាល

- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញក្រឹត្យ ចុះថ្ងៃទី ០២ ខែ កក្កដា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងសហអគ្គមេបញ្ជាការ នៃកងកម្លាំងប្រដាប់អាវុធជាតិកម្ពុជា
- បានឃើញក្រឹត្យ ចុះថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ១៩៩៣ ស្តីពីការបង្កើតក្រសួងការពារជាតិ
- បានឃើញក្រឹត្យ ចុះថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ១៩៩៣ ស្តីពីការបង្កើតអគ្គសេនាធិការដ្ឋាន នៃកងទ័ពជាតិកម្ពុជា
- បានឃើញយោបល់របស់ទីប្រឹក្សាខាងកិច្ចការពារជាតិនិងក្រុមប្រឹក្សាអ្នកច្បាប់អមនាយករដ្ឋមន្ត្រី

សំរេច

មាត្រា ១ : កងរាជអាវុធហត្ថ ដែលឋិតនៅក្រោមការគ្រប់គ្រងរបស់អគ្គសេនាធិការកងយោធពលខេមរភូមិន្ទ នោះ ត្រូវឋិតនៅក្រោមបញ្ជាផ្ទាល់របស់នាយករដ្ឋមន្ត្រី ។

មាត្រា ២ : នាយករដ្ឋមន្ត្រី ជាអ្នកកំណត់គោលនយោបាយទូទៅ ។

សហរដ្ឋមន្ត្រីក្រសួងការពារជាតិ ជាអ្នកទទួលខុសត្រូវលើផ្នែករដ្ឋបាលទូទៅ និង ជាអ្នកផ្តល់សំភារៈ និង ថវិកាសំរាប់ផ្គត់ផ្គង់កងរាជអាវុធហត្ថ តាមរយៈអគ្គសេនាធិការកងយោធពលខេមរភូមិន្ទ ។

មាត្រា ៣ : កងរាជអាវុធហត្ថ ជាផ្នែកមួយរបស់កងយោធពលខេមរភូមិន្ទ ដែលមានតួនាទីក្នុងកិច្ចអនុវត្តច្បាប់ ។ កងរាជអាវុធហត្ថមានសមត្ថភាពផ្នែកយុត្តិធម៌ ដែលមានឧបនិស្ស័យ ជាមន្ត្រីក្រសួង សមត្ថកិច្ចកងរាជអាវុធហត្ថ ត្រូវអនុវត្តពេញផ្ទៃប្រទេសទាំងមូលទៅលើពលរដ្ឋស៊ីវិល ព្រមទាំងទៅលើយោធាក្នុងជួរកងទ័ពផង ។

មាត្រា ៤ : កងរាជអាវុធហត្ថមានភារកិច្ច ÷

ក- កាន់កាប់សកម្មភាពខាងប៉ូលីសរដ្ឋបាល :

- រក្សាសុវត្ថិភាព និង សណ្តាប់ធ្នាប់សាធារណៈទូទៅ
- កាន់កាប់អោយមានការគោរពច្បាប់ និង បទបញ្ញាទាំងឡាយ
- ផ្តល់ពត៌មាន និង ជួយសង្គ្រោះពលរដ្ឋស៊ីវិល ។

ក្នុងករណី នៃការអនុវត្តន៍ភារកិច្ចនេះ កងរាជអាវុធហត្ថ អាចនឹងទទួលបញ្ជា ពីសហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អាជ្ញាធររដ្ឋបាលមានសមត្ថកិច្ច ។

ខ- កាន់កាប់សកម្មភាពខាងប៉ូលីសតុលាការ :

- ពិនិត្យកត់ត្រានូវឧក្រិដ្ឋកម្ម និង ទោសកម្ម
- ធ្វើកំណត់ហេតុអំពីបទល្មើស
- ប្រមូលផ្តុំភស្តុតាងផ្សេងៗ
- ស្រាវជ្រាវរាវរកអ្នកប្រព្រឹត្តបទល្មើស ដើម្បីបញ្ជូនខ្លួនទៅតុលាការ តាមដីកាតុលាការ
- ទទួលបន្ទុកអនុវត្ត តាមដីកាផ្ទេរអំណាចពីចៅក្រមស៊ើបសួរ ។

ក្នុងករណីអនុវត្តភារកិច្ចនេះ កងរាជអាវុធហត្ថអាចនឹងទទួលបទបញ្ជាពីរដ្ឋមន្ត្រី ក្រសួងយុត្តិធម៌ អង្គការអយ្យការ និង អាជ្ញាធរ តុលាការមានសមត្ថកិច្ច ។

គ- បំពេញបេសកកម្ម ដែលមានលក្ខណៈពិសេសខាងយោធា :

- ទទួលបន្ទុករក្សាសុវត្ថិភាព និង បំពេញតួនាទីជាកងកិត្តិយសជាប្រយោជន៍ដល់ស្ថាប័ន
- ការការពារទីតាំងយោធា
- កិច្ចការប៉ូលីសយោធានៅក្នុង ឬ ក្រៅទីតាំងកងទ័ព ។

ក្នុងករណីអនុវត្តភារកិច្ចនេះ កងរាជអាវុធហត្ថអាចនឹងទទួលបញ្ជាពីសហរដ្ឋមន្ត្រីក្រសួងការពារជាតិ នាយអគ្គសេនាធិការកងយោធពលខេមរភូមិន្ទ និង អាជ្ញាធរយោធា មានសមត្ថកិច្ច ។

ឃ- ផ្តល់កំលាំងទៅជួយក្រសួងនានា ដែលបានស្នើសុំតាមសេចក្តីត្រូវការជាចាំបាច់ ។

មាត្រា ៥ : កងរាជអាវុធហត្ថអាចនឹងទទួលបេសកកម្មផ្នែកប៉ូលីស ពិសេសបន្ថែមដោយអនុលោមតាមអនុក្រឹត្យក្នុងបច្ចាកាល ។

មាត្រា ៦ : រចនាសម្ព័ន្ធទូទៅរបស់កងរាជអាវុធហត្ថមាន :

- អធិការដ្ឋានកងរាជអាវុធហត្ថ
- នាយកដ្ឋានកងរាជអាវុធហត្ថ

មាត្រា ៧ : អធិការដ្ឋានកងរាជអាវុធហត្ថ

អធិការកងរាជអាវុធហត្ថមានភារកិច្ចបំពេញបេសកកម្មត្រួតពិនិត្យ សិក្សា និង ផ្តល់ព័ត៌មាន ។

អធិការកងរាជអាវុធហត្ថ ត្រូវឋិតនៅក្រោមបញ្ជានាយករដ្ឋមន្ត្រីផ្ទាល់ដែលជាអ្នកកំណត់បេសកកម្ម ។

អធិការកងរាជអាវុធហត្ថ ជាទីប្រឹក្សាអចិន្ត្រៃយ៍របស់នាយករដ្ឋមន្ត្រី ។ ក្នុងករណីនេះ អធិការកងរាជអាវុធហត្ថ ត្រូវផ្តល់យោបល់ដល់នាយករដ្ឋមន្ត្រី នូវគ្រប់គំរោងស្តីពីអនាគតផ្នែករចនាសម្ព័ន្ធ និង មុខងាររបស់កងរាជអាវុធហត្ថ ។ អធិការកងរាជអាវុធហត្ថតោងតែតាមពិនិត្យមើលដោយផ្ទាល់ នូវកិច្ចប្រតិបត្តិការងារ និង ការប្រើប្រាស់បុគ្គលិកកងរាជអាវុធហត្ថអោយសមស្របតាមច្បាប់ ។

មាត្រា ៨ : នាយកដ្ឋានកងរាជអាវុធហត្ថ

នាយកដ្ឋានកងរាជអាវុធហត្ថ ដឹកនាំដោយនាយកមួយរូប អាចជានាយទាហានថ្នាក់ឧត្តមសេនីយ៍ ឬ បុគ្គលិក ស៊ីវិលជាន់ខ្ពស់ មានភារកិច្ច :

- ចងក្រងបទបញ្ញត្តិការងារទូទៅ និង តាមពិនិត្យការអនុវត្តដោយមានទំនាក់ទំនងជាមួយក្រសួងពាក់ព័ន្ធ ដូចជាក្រសួងការពារជាតិ ក្រសួងមហាផ្ទៃ និង ក្រសួងយុត្តិធម៌ជាដើម ។
- ផ្តល់ព័ត៌មានដល់នាយករដ្ឋមន្ត្រីអំពីមធ្យោបាយគ្រប់យ៉ាងដែលមានភាពចាំបាច់ការងារបាន
- ដោះស្រាយកែសំរួលចំពោះបញ្ហាទាក់ទង ក្នុងការរៀបចំផ្នែករដ្ឋបាល និង ដំណើរការប្រព្រឹត្តិទៅរបស់កងរាជអាវុធហត្ថ ។

ឋិតនៅក្រោមបញ្ជារបស់ នាយកកងរាជអាវុធហត្ថ មាន :

- សាលាហ្វឹកហ្វឺនកងរាជអាវុធហត្ថ
- កងរាជអាវុធហត្ថផ្ទៃប្រទេស

- កងរាជអាវុធហត្ថចល័ត
- តម្រួតយោធា

មាត្រា ៩ : សាលាហ្វឹកហ្វឺនកងរាជអាវុធហត្ថ

សាលាហ្វឹកហ្វឺនកងរាជអាវុធហត្ថ ត្រូវទទួលបន្ទុក :

- រៀបចំកម្មវិធីបង្រៀន
- ហ្វឹកហ្វឺនបុគ្គលិក
- ត្រួតពិនិត្យការហ្វឹកហ្វឺន
- រៀបរៀង និង ចងក្រងឯកសារសំរាប់បង្រៀន

ធ្វើសំណើទៅនាយកដ្ឋានកងរាជអាវុធហត្ថ នូវសំភារៈជាចាំបាច់សំរាប់ដំណើរការសិក្សាអោយមានប្រសិទ្ធភាព ។

មាត្រា ១០: កងរាជអាវុធហត្ថខេត្តក្រុង

កងរាជអាវុធហត្ថខេត្តក្រុងដែលដាក់អោយអនុវត្តការងារនៅពេញផ្ទៃព្រះរាជាណាចក្រកម្ពុជា រហូតទៅដល់ថ្នាក់ ឃុំ ត្រូវទទួលបន្ទុកបំពេញបេសកកម្មរបស់កងរាជអាវុធហត្ថដែលមានចែងនៅក្នុងមាត្រា ៤ នៃអនុក្រឹត្យនេះ ។

សមត្ថកិច្ច នៃកងរាជអាវុធហត្ថខេត្តក្រុងអនុវត្តទៅលើពលរដ្ឋស៊ីវិល និង យោធា ។

មាត្រា ១១: កងរាជអាវុធហត្ថចល័ត

កងរាជអាវុធហត្ថចល័ត ជាកងកម្លាំងសំរាប់ការពារ អោយមានសណ្តាប់ធ្នាប់ និងប្រយុទ្ធប្រឆាំងនឹងក្រុមប្រដាប់អាវុធខុសច្បាប់ ។ កងរាជអាវុធហត្ថចល័តអនុវត្តការងារពេញផ្ទៃប្រទេសតាមការស្នើពីកងរាជអាវុធហត្ថខេត្តក្រុង ឬ តាមសំបុត្រកំណែនពីអាជ្ញាធរមានសមត្ថកិច្ច ផ្នែករដ្ឋបាល ឬ តុលាការ ។ កងរាជអាវុធហត្ថចល័តត្រូវត្រៀមខ្លួនជានិច្ចសំរាប់បន្ថែមកម្លាំងក្នុងពេលខ្លីបំផុតទៅជួយកងឯកភាពនៃកងរាជអាវុធហត្ថខេត្តក្រុង ។

មាត្រា ១២: តម្រួតយោធា

តម្រួតយោធា គឺ ជាកងកម្លាំងមួយនៃកងរាជអាវុធហត្ថ ដែលមានភារកិច្ចចុះទៅធ្វើការផ្ទាល់ជាមួយនិងកងទ័ពទាំង ៣ ប្រភេទ នៃកងយោធពលខេមរភូមិន្ទ ។ តម្រួតយោធាបំពេញ

បេសកកម្មនេះ ក្រោមបញ្ជាអាជ្ញាធរ ដូចមានចែងក្នុងវគ្គ " គ " នៃមាត្រា ៤ នៃអនុក្រឹត្យនេះ ។

មាត្រា១៣: អធិការ ឬ នាយកកងរាជអាវុធហត្ថអាចស្នើបង្កើតនូវអង្គភាពឯកទេសផ្សេងៗទៀត ដើម្បីប្រសិទ្ធភាពការងារក្នុងកាលៈទេសៈចាំបាច់ ។

មាត្រា១៤: ប្រគល់ជូនសហរដ្ឋមន្ត្រីការពារជាតិ និង នាយអគ្គសេនាធិការកងយោធពលខេមរភូមិន្ទ នូវនាទីកំណត់ភារកិច្ច ចំនួនជាក់ស្តែងនិងការស្នើតែងតាំង ក្នុងការរៀបចំស្ថាប័ន ដែលមានចែងខាងលើ ដោយមានការពិគ្រោះយោបល់ជាមួយសហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

មាត្រា១៥: បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយអំពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា១៦: សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងការពារជាតិ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ នាយអគ្គសេនាធិការកងយោធពលខេមរភូមិន្ទ និង គ្រប់ក្រសួងពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ដែលចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី១	នាយករដ្ឋមន្ត្រីទី២
ព្រះហស្តលេខានិងត្រា	ហត្ថលេខានិងត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ,ថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ១៩៩៤

អនុក្រឹត្យលេខ ២៦ អនក្រ

ស្តីពី និយត្តភាពសេវាធនាគាររបស់

ក្រសួងមហាផ្ទៃ ពីជំពូក ១១ មកជំពូក ១២

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ របស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុវរ្ម័ន** ព្រះ

បេសកកម្មនេះ ក្រោមបញ្ជាអាជ្ញាធរ ដូចមានចែងក្នុងវគ្គ “ គ ” នៃមាត្រា ៤ នៃអនុក្រឹត្យនេះ ។

មាត្រា១៣: អធិការ ឬ នាយកកងអាវុធហត្ថអាចស្នើបង្កើតនូវអង្គភាពឯកទេសផ្សេងៗទៀត ដើម្បីប្រសិទ្ធភាពការងារក្នុងកាលៈទេសៈចាំបាច់ ។

មាត្រា១៤: ប្រគល់ជូនសហរដ្ឋមន្ត្រីការពារជាតិ និង នាយអគ្គសេនាធិការកងយោធពលខេមរភូមិន្ទ នូវនាទីកំណត់ភារកិច្ច ចំនួនជាក់ស្តែងនិងការស្នើតែងតាំង ក្នុងការរៀបចំស្ថាប័ន ដែលមានចែងខាងលើដោយមានការពិគ្រោះយោបល់ជាមួយសហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

មាត្រា១៥: បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយអំពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា១៦: សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងការពារជាតិ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ នាយអគ្គសេនាធិការកងយោធពលខេមរភូមិន្ទ និង គ្រប់ក្រសួងពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ដែលចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី១	នាយករដ្ឋមន្ត្រីទី២
ព្រះហស្តលេខានិងត្រា	ហត្ថលេខានិងត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ,ថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ១៩៩៤

អនុក្រឹត្យលេខ ២៦ អនក្រ
ស្តីពី និយ័តភាពឥណទានរបស់
ក្រសួងមហាផ្ទៃ ពីជំពូក ១១ មកជំពូក ១២

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ របស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុវរ្ម័ន** ព្រះ

មហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

- បានឃើញច្បាប់ ស្ដីពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ០១ ន.ស ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣
- បានឃើញច្បាប់ហិរញ្ញវត្ថុ សំរាប់ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ០២ ន.ស ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣
- បានឃើញអនុក្រឹត្យលេខ ០១ អនក្រ ចុះថ្ងៃទី ០៥ ខែ មករា ឆ្នាំ ១៩៩៤ ស្ដីពីការបែងចែកឥណទានតាមជំពូក នៃច្បាប់ហិរញ្ញវត្ថុ សំរាប់ឆ្នាំ ១៩៩៤
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

សំរេច

មាត្រា ១ : ថវិការបស់ក្រសួងមហាផ្ទៃ សំរាប់ឆ្នាំ ១៩៩៤ ត្រូវបានកែសំរួលដោយធ្វើនិយត្តភាពដូចតទៅ ÷

- ផ្នែកទី ១ : សន្តិសុខសាធារណៈ
- ប្រភេទ ១ : មធ្យោបាយសេវា
- ជំពូក ១១ : ចំណាយដំណើរការរដ្ឋបាល សំភារៈ និងការជួសជុលតូច

និយត្តភាពបញ្ចូលទៅ :

- ផ្នែកទី ២ : រដ្ឋបាលទូទៅ
- ប្រភេទ ១ : មធ្យោបាយសេវា
- ជំពូក ១២ : ប្រាក់ឧបត្ថម្ភ សំរាប់ដំណើរការ អង្គការសាធារណៈ រដ្ឋបាល
- ទឹកប្រាក់បន្ថែម : ៣៩៤៦.៣១៦.០០០ រៀល ។

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អភិបាលគ្រប់ខេត្ត-ក្រុង ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀង ៗ ខ្លួន ចាប់ពីថ្ងៃឡាយព្រះហស្ដលេខា និង ចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី១	នាយករដ្ឋមន្ត្រីទី២
ព្រះហស្ដលេខា និងត្រា	ហត្ថលេខា និងត្រា
នរោត្ដម រណឫទ្ធិ	**ហ៊ុន សែន**

រាជធានីភ្នំពេញ,ថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ១៩៩៤

អនុក្រឹត្យលេខ ២៧ អនក្រ
ស្តីពីការកំណត់របបប្រាក់ឧបត្ថម្ភ
ចំពោះ មន្ត្រី ឃុំ សង្កាត់ និង ភូមិ

* * *

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ របស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុវរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ០១ ន.ស ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣
- បានឃើញច្បាប់ហិរញ្ញវត្ថុសំរាប់ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ០២ ន.ស ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣
- បានឃើញអនុក្រឹត្យលេខ ០១ អនក្រ ចុះថ្ងៃទី ០៥ ខែ មករា ឆ្នាំ ១៩៩៤ ស្តីពីការបែងចែកឥណទានតាមជំពូក នៃច្បាប់ហិរញ្ញវត្ថុ សំរាប់ឆ្នាំ ១៩៩៤
- តាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សំរេច

មាត្រា ១ ចាប់ពីថ្ងៃទី ០១ ខែ ឧសភា ឆ្នាំ ១៩៩៤ របបប្រាក់ឧបត្ថម្ភប្រចាំខែ ចំពោះមន្ត្រី ឃុំ សង្កាត់ និង ភូមិ ត្រូវបានកំណត់ដូចតទៅ ÷

នៅថ្នាក់ឃុំ :	- ប្រធានឃុំ	:	៣០.០០០ រៀល ក្នុង ១ ខែ
	- ជំទប់ឃុំម្នាក់	:	២៧.០០០ រៀល ក្នុង ១ ខែ
	- ជំនួយការម្នាក់		២៣.៥០០ រៀល ក្នុង ១ ខែ

នៅថ្នាក់សង្កាត់ : - ចៅសង្កាត់ : ៣០.០០០ រៀល ក្នុង ១ ខែ

- ចៅសង្កាត់រងម្នាក់ : ២៧.០០០ រៀល ក្នុង ១ ខែ

- ជំនួយការម្នាក់ : ២៣.៥០០ រៀល ក្នុង ១ ខែ

នៅថ្នាក់ភូមិ : - ប្រធានភូមិ : ២២.០០០ រៀល ក្នុង ១ ខែ

មាត្រា ២ : ផ្តល់ថវិកាសំរាប់ទិញសំភារៈការិយាល័យ : ១០.០០០ " មួយម៉ឺនរៀលគត់ " ក្នុង ១ ខែ ក្នុង ១ ឃុំ សង្កាត់ ។

មាត្រា ៣ : សេចក្តីកំណត់របបប្រាក់ឧបត្ថម្ភរបស់ មន្ត្រី ឃុំ សង្កាត់ និង ភូមិ កន្លងមកដែលផ្ទុយនឹងខ្លឹមសារ នៃអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៤ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អភិបាលគ្រប់ខេត្ត- ក្រុង ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀង ៗ ខ្លួន គាប់ពីថ្ងៃឡាយព្រះហស្ថលេខា និង ចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី១ **នាយករដ្ឋមន្ត្រីទី២**

ព្រះហស្ថលេខា និងត្រា ហត្ថលេខា និងត្រា

នរោត្តម រណឫទ្ធិ **ហ៊ុន សែន**

***

រាជធានីភ្នំពេញ, ថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ១៩៩៤

អនុក្រឹត្យលេខ ៥១ អនក្រ

ស្តីពីការតម្លើងឋានន្តរសក្តិជាកិច្ចបច្ចាមរណៈ

* * *

រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា

- បានឃើញព្រះរាជក្រឹត្យ របស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុវរ្ម័ន ព្រះ